FARMER NOTES
ព្រឹត្តិប័ត្រព័ត៌មានកសិករ
ឆ្នាំទី ៧ លេខ ៦៨ ខែមករា ឆ្នាំ ២០០៨
ការចេញផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
A Publication of the Cambodian Agricultural Research and Development Institute



# ក្រុមដីសំខាន់ៗនៃដំណាំស្រូវក្នុងប្រទេសកម្ពុជា



## ១-ក្រុមដី ព្រៃខ្មែរ

ជាប្រភេទដីម្យ៉ាងដែលកើតឡើងលើទំនាបល្បាប់ជំនន់ចាស់ ឬទំនាបល្បាប់ជំនន់ល្បាប់សំណឹក ដែលវាយនភាពនៃប្រូហ្វីល មានលក្ខណៈជាខ្សាច់ជម្រៅជាង ៥០ ស.ម។ ដីប្រភេទនេះមានប្រមាណ ១១ ភាគរយ នៃដីដាំដុះស្រូវសរុប។ ដីនេះត្រូវបានគេបែងចែកជាពីអនុក្រុមខុសគ្នា៖ មួយគឺអនុក្រុមខ្សាច់ម៉ត់ និងមួយទៀតអនុក្រុមខ្សាច់គ្រើម។

ក្រុមដីព្រៃខ្មែរលំបាកក្នុងការគ្រប់គ្រង សម្រាប់ផលិតកម្មដំណាំស្រូវ។ ដីនេះពុំសមស្របចំពោះការស្រោចស្រពទេ ហើយជីជាតិនៃដីក៏តិចដែរ។ តាមការពិសោធន៍នៅផ្ទះកញ្ចក់បង្ហាញថា ដីនេះកើតមាននូវកង្វះសារធាតុ N, P, K, S និង Mg។ មិនតែប៉ុណ្ណោះកម្រិតនៃសារធាតុសរីរាង្គទាប ហើយការគ្រប់គ្រងជីជាតិមានការលំបាក ដោយសារដីនេះងាយជ្រាបទឹក និងមានការលំបាកក្នុងការតម្រូវអាហារធាតុ ទៅនឹងសេចក្តីត្រូវការរបស់ដំណាំ។



## ២-ក្រុមដី ប្រទះឡាង

ជាប្រភេទដីកើតឡើងលើទំនាបល្បាប់ជំនន់ចាស់ ឬទំនាបល្បាប់ជំនន់ ជាល្បាប់សំណឹក ដែលមានខ្សាច់កម្រាស់តិចជាង ៤០ ស.ម ដីស្រទាប់ក្រោមមានវាយនភាពល្បាប់ ឬឥដ្ឋ។

ដីប្រភេទនេះជាដីដំណាំស្រូវទូទៅ និងមានប្រមាណ ២៨ ភាគរយ នៃតំបន់ដាំដុះសរុប។ ក្រុមដីប្រទះឡាងត្រូវបានគេធ្វើចំណាត់ថ្នាក់ជា ៣ អនុក្រុមផ្សេងគ្នា ដោយផ្អែកលើលក្ខណៈនៃដីស្រទាប់ក្រោម ដែលមានឥទ្ធិពលលើការចាក់ឬសរបស់ដំណាំ និងការជ្រាបទឹក។ អនុក្រុមទាំងនោះមាន៖ អនុក្រុមរាក់ អនុក្រុមដីឥដ្ឋស្រទាប់ក្រោម និងអនុក្រុមដីល្បាយស្រទាប់ក្រោម។ ដីនេះមានការលំបាកក្នុងការគ្រប់គ្រង ចំពោះផលិតកម្មដំណាំស្រូវ។ ប្រសិនបើរចនាសម្ព័ន្ធសម្រាប់ការស្រោចស្រព និងប្រើប្រាស់ទឹកអាចត្រូវបានប្រើក្នុងតម្លៃថោក នោះគេសង្ឃឹមថានឹងទទួលទិន្នផលចំណេញ។



## ៣-ក្រុមដី ឡាបានសៀក

ដីឡាបានសៀក កើតមាននៅតាមជើងភ្នំ ឬនៅលើភ្នំដែលមានដីពណ៌ក្រហម ផ្ទៃខាងលើមានវាយនភាពជាឥដ្ឋ មានទម្រង់ខ្ទេច ហើយស្រទាប់ក្រោមមានវាយនភាពជាឥដ្ឋដែរ។ ដីនេះមានតិចជាង ១ ភាគរយ នៃផ្ទៃដីដាំស្រូវសរុប។ ដីឡាបានសៀក មានជីជាតិមធ្យម កម្រិតនៃសារធាតុសរីរាង្គ ប្រែប្រួលពីមធ្យមទៅខ្ពស់ ហើយសមស្របទៅនឹងផលិតកម្មស្រូវចម្ការ។

ការពិសោធន៍នៅផ្ទះកញ្ចក់បានបង្ហាញថា ដីនេះខ្វះធាតុ អាសូត ផូស្វ័រ ប៉ូតាស្យូម និង ស្ពាន់ធ័រនៅលើស្រែ។ ជាទូទៅក្រុមដីនេះ ជាដីដែលមានលក្ខណៈអាស៊ីតខ្សោយ តែវាអាចមានលក្ខណៈជាដីអាល់កាឡាំងដែរ។

## ៤-ក្រុមដី បាកាន




ដីបាកាន កើតឡើងនៅលើទំនាបល្បាប់ចាស់ និងល្បាប់ជំនន់ ឬល្បាប់។ ដីស្រទាប់លើជាល្បាយ ឬឥដ្ឋ ពុំមានវត្ថមានក្រហែងទេ ឬបើមានគឺមានតែនៅផ្ទៃដីលើរាក់ៗប៉ុណ្ណោះ។ ដីស្រទាប់ក្រោមជាដីល្បាយ ឬឥដ្ឋមានស្នាមចម្រុះ។

ក្រុមដីបាកាន មានប្រហែល ១២ ភាគរយ នៃដីដាំដុះស្រូវ ក្នុងប្រទេសកម្ពុជា ហើយដីនេះសមស្របទៅនឹងផលិតកម្មស្រូវ។ ការគ្រប់គ្រងទឹកបានល្អ គឺជាលក្ខខណ្ឌដ៏ប្រសើរសម្រាប់ការបង្កើនទិន្នផលស្រូវ។ ដីនេះមានជីជាតិមធ្យម តាមការពិសោធន៍នៅផ្ទះកញ្ចក់បង្ហាញថា ដីនេះជួបបញ្ហាខ្វះជីធាតុ អាសូត ផូស្វ័រ ប៉ូតាស្យូម និងអាចខ្វះស្ពាន់ធ័រ ទៀតផង។ នៅតាមស្រែ គេសង្កេតឃើញថា វាហាក់បីដូចជាមានការឆ្លើយតបទៅនឹងការប្រើប្រាស់ជីជាតិអាសូត ផូស្វ័រ និងប៉ូតាស្យូម។

## ៥-ក្រុមដី ទួលសំរោង

ដីនេះកើតឡើងនៅលើល្បាប់ជំនន់ចាស់ ឬល្បាប់សំណឹក ដែលមានវាយនភាពស្រទាប់លើជាឥដ្ឋ ឬល្បាយ។ ដីនេះ មានក្រហែងធំជម្រៅជ្រៅជាង ៥ ស.ម ស្រទាប់ក្រោមជាឥដ្ឋ ឬល្បាយ។ ដីស្រទាប់លើមានពណ៌ប្រផេះ ឬត្នោត ប៉ុន្តែមិនមែនប្រផេះក្រមៅ ឬខ្មៅទេ។

ក្រុមដីទួលសំរោងមានប្រហែល ១០ ភាគរយ នៃផ្ទៃដីដាំស្រូវ។ ដីនេះចែកជាពីរអនុក្រុមអាស្រ័យទៅតាមពណ៌ និងជីជាតិរបស់ដី គឺអនុក្រុមពណ៌ត្នោត និងអនុក្រុមពណ៌ប្រផេះ។

ដីនេះសមស្របចំពោះផលិតកម្មស្រូវ ពោលគឺមានសក្តានុពលពីបង្គួរទៅខ្ពស់ ហើយមានការឆ្លើយតបល្អ ចំពោះការគ្រប់គ្រងកែច្នៃ ពិសេសចំពោះការស្រោចស្រព។

តាមការសង្កេតកន្លងមក ដីនេះមានការឆ្លើយតបល្អ ចំពោះតែការប្រើប្រាស់ អាសូត និង ផូស្វ័រប៉ុណ្ណោះ។




## ៦- ក្រុមដី កំពង់សៀម




ក្រុមដីកំពង់សៀម កើតឡើងនៅលើផ្នែកនៃសណ្ឋានដីប្រែប្រួលខ្ពស់ទាបមិនរាបស្មើ ដែលមានវាយនភាពស្រទាប់លើជាដីឥដ្ឋមានពណ៌ខ្មៅ ឬប្រផេះក្រមៅ មានក្រហែងធំជ្រៅ ដីស្រទាប់ក្រោមជាដីឥដ្ឋពណ៌ប្រផេះ។ ក្រុមដីនេះជាដីក្មេងមានប្រហែល ២ ភាគរយ នៃផ្ទៃដីដាំស្រូវទាំងអស់នៅប្រទេសកម្ពុជា។ ដីនេះត្រូវបានចែកចេញជាពីរអនុក្រុមដោយផ្អែក ទៅលើវត្តមាន និងអវត្តមាននៃក្រួស។

ដីនេះសមស្របសម្រាប់ផលិតកម្មស្រូវ ឯទិន្នផលឆ្លើយតបល្អទៅនឹងការគ្រប់គ្រងបែបទំនើប។ ការពិសោធន៍នៅផ្ទះកញ្ចក់បានបង្ហាញថា ក្រុមដីកំពង់សៀម មានកង្វះសារធាតុអាសូត និងផូស្វ័រ។ ជម្រៅរបស់ឫស មិនមានការកំណត់ទេ សមត្ថភាពស្តុកទឹកទុករបស់ដីស្រទាប់លើល្អ ប៉ុន្តែក្នុងកំឡុងពេលមានភ្លៀងតិច ដីនេះអាចហួតហែងដោយសារតែវាអាចស្តុកទឹកបានតិចតួច។

សម្រាប់ព័ត៌មានបន្ថែមសូមធ្វើការទាក់ទង ការិយាល័យវិទ្យាសាស្ត្រដី ទឹក មជ្ឈមណ្ឌលបណ្តុះបណ្តាល និងព័ត៌មាន ការិយាល័យផែនការ សហប្រតិបត្តិការ និងពាណិជ្ជកម្ម នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៅតាមបណ្តោយផ្លូវជាតិលេខ ៣ សង្កាត់ប្រទះឡាង ខណ្ឌដង្កោ រាជធានីភ្នំពេញ ឬតាមប្រអប់សំបុត្រលេខ ០១ ភ្នំពេញ
ទូរស័ព្ទលេខ: (៨៥៥-២៣) ៦៣១៩ ៦៩៣-៤ គេហទំព័រ: www.cardi.org.kh
ទូរអក្ខរ: vseng@cardi.org.kh trin@cardi.org.kh hunyadana@cardi.org.kh